ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

នស/រកត/១២២៣/២៦៥២

## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅ
## នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ព្រះរាជក្រឹត្យនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដែលហៅជាអក្សរកាត់ថា **គ.ក.ប.យ.** ដើម្បីជាយន្តការដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅពង្រឹង និងលើកកម្ពស់[illegible]ព្រមទាំងគុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## តួនាទី និងភារកិច្ចរបស់ គ.ក.ប.យ.

**មាត្រា២ ._**

**គ.ក.ប.យ.** មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ គាំទ្រ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- ផ្តួចផ្តើម និងលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច លើផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ ផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ដាក់ចេញនូវសេចក្តីណែនាំ និងវិធានការចាំបាច់នានាសំដៅធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ព័ន្ធនឹងការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យយុត្តិធម៌
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដើម្បីជំរុញ និងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- លើកសំណើជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេចលើប្រព័ន្ធលើកទឹកចិត្តសម្រាប់គាំទ្រដល់ការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងលើកសំណើវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈមជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ជំរុញការផ្សព្វផ្សាយសមិទ្ធផលនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- អនុវត្តការងារផ្សេងទៀតពាក់ព័ន្ធនឹងការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌។

## ជំពូកទី៣
## សមាសភាពរបស់ គ.ក.ប.យ.

**មាត្រា៣ ._**

**គ.ក.ប.យ.** មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| - ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | សហប្រធាន |
| - ប្រធានតុលាការកំពូល | | សហប្រធាន |
| - អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល | | អនុប្រធានទី១ |
| - តំណាងអង្គភាពប្រឆាំងអំពើពុករលួយ | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១រូប | អនុប្រធានប្រចាំការ |
| - អនុប្រធានតុលាការកំពូល | ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | សមាជិក |



ចងក្រងដោយ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
- រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប សមាជិក
- ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ សមាជិក
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ សមាជិក
- តំណាងអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ១រូប សមាជិក
- ប្រធានបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិក
- ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា សមាជិក
- អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ នៃក្រសួងយុត្តិធម៌ សមាជិក
- តំណាងក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌ ១រូប សមាជិក
- ប្រធានសាលាដំបូងរាជធានីភ្នំពេញ សមាជិក
- ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ សមាជិក
- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** សមាជិក។

**គ.ក.ប.យ.** អាចមានសមាសភាពបន្ថែមផ្សេងទៀតជាអនុប្រធាន ឬសមាជិក តាមការចាំបាច់ ដែលជាឥស្សរជនតំណាងក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាល ឬជ្រើសរើសចេញពីសាលាជម្រះក្តី ឬអង្គការអយ្យការអមសាលាជម្រះក្តី ឬចេញពីក្នុងចំណោមឥស្សរជនដែលមានបទពិសោធន៍ការងារខ្ពស់ក្នុងកិច្ចការកែទម្រង់កិច្ចការច្បាប់ ឬកិច្ចការយុត្តិធម៌។

សមាសភាពជាក់ស្តែង និងសមាសភាពបន្ថែមនៃ **គ.ក.ប.យ.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

**គ.ក.ប.យ.** អាចមានទីប្រឹក្សាមួយចំនួន តាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ក.ប.យ.

**មាត្រា៤ ..**

សហប្រធាន **គ.ក.ប.យ.** ដឹកនាំកិច្ចការទូទៅរបស់ **គ.ក.ប.យ.**។ សហប្រធានអាចប្រគល់សិទ្ធិជូនសហប្រធានណាម្នាក់ ឬអនុប្រធានណាម្នាក់ដើម្បីដឹកនាំការងារប្រចាំថ្ងៃជំនួសបាន។

**មាត្រា៥ ..**

**គ.ក.ប.យ.** ត្រូវរៀបចំឱ្យមានកិច្ចប្រជុំជាទៀងទាត់រៀងរាល់ត្រីមាស ឬតាមការចាំបាច់។ **គ.ក.ប.យ.** ត្រូវរៀបចំកិច្ចប្រជុំប្រចាំឆ្នាំដើម្បីត្រួតពិនិត្យអំពីវឌ្ឍនភាពការងារ និងលើកទិសដៅការងារបន្ត ព្រមទាំងធ្វើរបាយការណ៍ប្រចាំឆ្នាំជូនប្រមុខរាជរដ្ឋាភិបាល។ កិច្ចប្រជុំរបស់ **គ.ក.ប.យ.** ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់សហប្រធាន **គ.ក.ប.យ.** ទាំងពីរ ឬរបស់សហប្រធានណាម្នាក់។ ក្នុងករណីចាំបាច់ សហប្រធាន **គ.ក.ប.យ.** អាចប្រគល់សិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**គ.ក.ប.យ.** អាចអញ្ជើញតំណាងក្រសួងនិងស្ថាប័នពាក់ព័ន្ធ សាលាជម្រះក្តីនិងអង្គការអយ្យការអមសាលាជម្រះក្តីពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិនិងអន្តរជាតិ ចូលរួមប្រជុំ តាមការចាំបាច់។

**មាត្រា៦** .-

**គ.ក.ប.យ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

**មាត្រា៧** .-

សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ព្រមទាំងស្ថាប័ន និងអង្គភាពដែលមានការពាក់ព័ន្ធនឹងការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ អាចបង្កើត "**ក្រុមការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌**" មួយនៅក្នុងស្ថាប័ន និងអង្គភាពរបស់ខ្លួន តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ស្របតាមព្រះរាជក្រឹត្យនេះ។

តួនាទី ភារកិច្ច និងសមាសភាពរបស់ក្រុមការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌នេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាសហប្រធាន **គ.ក.ប.យ.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសហប្រធាន **គ.ក.ប.យ.** ដែលជាប្រធានតុលាការកំពូល។

**មាត្រា៨** .-

**គ.ក.ប.យ.** ត្រូវរៀបចំប្រព័ន្ធលើកទឹកចិត្ត ផ្អែកលើសមិទ្ធកម្មសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការដែលចូលរួមនៅក្នុងការអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

## ជំពូកទី៥
## អគ្គលេខាធិការដ្ឋាន គ.ក.ប.យ.

**មាត្រា៩** .-

**គ.ក.ប.យ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ស្ថិតក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ ដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់ខ្លួន។ រចនាសម្ព័ន្ធចំណុះអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ត្រូវបែងចែកជានាយកដ្ឋាន។

អគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់។ នាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន តាមការចាំបាច់។

អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាសហប្រធាន **គ.ក.ប.យ.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសហប្រធាន **គ.ក.ប.យ.** ដែលជាប្រធានតុលាការកំពូល។

ប្រធាននាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន **គ.ក.ច.យ.** ត្រូវតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់មុខតំណែងដោយអនុក្រឹត្យ តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាសហប្រធាន **គ.ក.ច.យ.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសហប្រធាន **គ.ក.ច.យ.** ដែលជាប្រធានតុលាការកំពូល។ មន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.យ.** ចាប់ពីអនុប្រធាននាយកដ្ឋានចុះក្រោម ត្រូវតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់មុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាសហប្រធាន **គ.ក.ច.យ.** បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសហប្រធាន **គ.ក.ច.យ.** ដែលជាប្រធានតុលាការកំពូល។

**មាត្រា១០ ..**

អគ្គលេខាធិការដ្ឋាន **គ.ក.ច.យ.** មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងការងារបច្ចេកទេសរបស់ **គ.ក.ច.យ.**
- សិក្សា ស្រាវជ្រាវ និងរៀបចំសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីដាក់ជូន **គ.ក.ច.យ.** ពិនិត្យ និងសម្រេច
- សហការ សម្របសម្រួល និងផ្ដល់ការគាំទ្រនិងជំនួយបច្ចេកទេសតាមការចាំបាច់ ដល់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តផែនការសកម្មភាពកែទម្រង់ប្រព័ន្ធយុត្តិធម៌ តាមការចង្អុលបង្ហាញរបស់ **គ.ក.ច.យ.**
- រៀបចំសេចក្ដីព្រាងប្រព័ន្ធលើកទឹកចិត្ត ប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព ក្នុងការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំសេចក្ដីព្រាងសូចនាករសមិទ្ធកម្មគន្លឹះ សម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីដាក់ជូន **គ.ក.ច.យ.** ពិនិត្យ និងសម្រេច
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកែទម្រង់ប្រព័ន្ធយុត្តិធម៌
- ផ្ដល់យោបល់ និងលើកសំណើដំណោះស្រាយជូន **គ.ក.ច.យ.** លើបញ្ហាប្រឈម និងបញ្ហាបច្ចេកទេសនានា ដើម្បីជំរុញល្បឿន និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ និងអន្តរជាតិ លើការងារពាក់ព័ន្ធនឹងការកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ជូន **គ.ក.ច.យ.**
- រៀបចំសេចក្ដីព្រាង និងផ្សព្វផ្សាយព័ត៌មានអំពីសមិទ្ធផលនានានៃការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រដំណើរការការងាររបស់ **គ.ក.ប.យ.** និងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **គ.ក.ប.យ.**
- អនុវត្តភារកិច្ចផ្សេងទៀតដែល **គ.ក.ប.យ.** ប្រគល់ឱ្យ។

**មាត្រា១១ ..**

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១២ ..**

មន្ត្រីបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន **គ.ក.ប.យ.** ត្រូវជ្រើសរើសចេញពីក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌនៃក្រសួងយុត្តិធម៌ ឬក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធផ្សេងទៀត ដែលមានគុណវុឌ្ឍិ និងបទពិសោធន៍សមស្របតាមលក្ខខណ្ឌការងារតម្រូវនីមួយៗ។ ក្នុងករណីចាំបាច់ **គ.ក.ប.យ.** អាចជ្រើសរើសអ្នកជំនាញការជាតិឬអន្តរជាតិ មន្ត្រីជាប់កិច្ចសន្យា និងមន្ត្រីរាជការនៃមុខងារសាធារណៈផ្សេងទៀត ដោយផ្អែកលើគោលការណ៍សមត្ថភាព តម្លាភាព និងការប្រកួតប្រជែងបើកទូលាយ។

## ជំពូកទី៦
## ប្រភពធនធាន និងថវិការបស់ គ.ក.ប.យ.

**មាត្រា១៣ ..**

**គ.ក.ប.យ.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងយុត្តិធម៌។

**គ.ក.ប.យ.** មានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងមូលនិធិ និងអំណោយដែលបានពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់ប្រើប្រាស់ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

ក្រុមការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធនឹងការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ មានប្រភពធនធានសម្រាប់ដំណើរការការងារស្ថិតក្នុងកញ្ចប់ថវិការបស់ស្ថាប័ន ឬអង្គភាពសាមីនោះ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា១៤ ..**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលពាក់ព័ន្ធនឹងការតែងតាំងសមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១៥ ..**

អនុក្រឹត្យលេខ ៩៩១ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦ ..**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ៣រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២៣

**នរោត្តម សីហមុនី**

នស/រកត/១២២៣/២៥០៥

**បានប្រូវខាប់ព្រះរាជលញ្ឆករហើយ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**